វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- សន្និសីទរបស់ធនាគារជាតិនៃកម្ពុជាលើកឡើងពីភាពទន់ខ្សោយនៃបច្ចេកវិទ្យាហិរញ្ញវត្ថុដែលជាការរារាំងដល់សេដ្ឋកិច្ច
- អតិផរណាមានការធ្លាក់ចុះនៅប្រទេសវៀតណាម
- ការបិទទ្វាររបស់រដ្ឋាភិបាលអាមេរិកបានធ្វើអោយខាតបង់ដល់សេដ្ឋកិច្ច ចំនួន០៣ប៊ីលានដុល្លារអាមេរិក

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តន៍នៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### សន្និសីទរបស់ធនាគារជាតិនៃកម្ពុជាលើកឡើងពីភាពទន់ខ្សោយនៃបច្ចេកវិទ្យាហិរញ្ញវត្ថុដែលជាការរារាំងដល់សេដ្ឋកិច្ច

ថ្លែងនៅក្នុងសន្និសីទប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជាកាលពីសប្តាហ៍មុន មន្ត្រីជាន់ខ្ពស់របស់ធនាគារជាតិនៃកម្ពុជាមួយចំនួនបានបង្ហាញការព្រួយបារម្ភទៅលើការទទួលយកនូវបច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) ដែលមានលក្ខណៈយឺតយ៉ាងនៅកម្ពុជា។ ពួកគេបានលើកឡើងថាការទទួលយកដ៏យឺតយ៉ាវរបស់កម្ពុជានូវបច្ចេកវិទ្យាហិរញ្ញវត្ថុ គឺជាការបន្ថយល្បឿនសេដ្ឋកិច្ច និង រារាំងការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុរបស់ធនាគារ ។

បច្ចេកវិទ្យាហិរញ្ញវត្ថុ រួមមានសេវាកម្មទូលំទូលាយ ដូចជា ប្រព័ន្ធទូទាត់ចល័ត, សេវាកម្មទូទាត់ប្រាក់តាមប្រព័ន្ធអ៊ិនធ័រណេតដោយគ្មានអន្តរការី និងសេវាកម្មឥណទាន, ការផ្តល់ប្រាក់កម្ចីពីដៃគូទៅវិញទៅមក និងបច្ចេកវិទ្យាផ្សេងទៀត ដែលត្រូវបានបង្កើតឡើងដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការ និងបង្កើនប្រសិទ្ធភាពនៃមូលធនដែលប្រើដោយក្រុមហ៊ុន និងអ្នកប្រើប្រាស់។

ធនាគារជាតិនៃកម្ពុជាកំពុងបង្កើតក្របខ័ណ្ឌគតិយុត្តិ និងគោលនយោបាយផ្សេងៗទៀត ដើម្បីលើកកម្ពស់វិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនេះ។ ប៉ុន្តែ កម្ពុជាក៏មានចំនុចវិជ្ជមានខ្លះៗដែរ ព្រោះកម្ពុជាបានទទួលយកនូវបច្ចេកវិទ្យាតាមរយៈទូរស័ព្ទស្មាតហ្វូន និងបច្ចេកវិទ្យាអ៊ីនធ័រណេតយ៉ាងឆាប់រហ័ស។

កាលពីឆ្នាំមុន ធនាគារចំនួន២៤ បានផ្តល់ជូនប្រព័ន្ធធនាគារតាមប្រព័ន្ធអ៊ិនធ័រណេត ខណៈធនាគារចំនួន១៩ បានផ្តល់ការប្រើប្រាស់នូវសេវាធនាគារតាមរយៈទូរស័ព្ទចល័ត។ លើសពីនេះទៀត ប្រតិបត្តិការចំនួន៨០ពាន់ ដែលមានតម្លៃស្មើនឹង៣,៨ប៊ីលានដុល្លារអាមេរិក ត្រូវបានប្រើប្រាស់នៅក្នុងប្រព័ន្ធធនាគារតាមអ៊ិនធ័រណេត និង១២,៣លានប្រតិបត្តិការដែលមានតម្លៃ ៥,៧ប៊ីលានដុល្លារអាមេរិកបានប្រើប្រព័ន្ធធនាគារតាមរយៈទូរសព្ទចល័ត។

### តារាងប្រចាំសប្តាហ៍៖ ឱនភាពពាណិជ្ជកម្មរបស់កម្ពុជា

តារាងប្រចាំសប្តាហ៍នេះបង្ហាញពីឱនភាពពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា គិតពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨។ ឱនភាពពាណិជ្ជកម្មកាលពីឆ្នាំមុន មានចំនួន៥ ២២២លានដុល្លារអាមេរិក កើនឡើង ២២% ធៀបនឹងឆ្នាំ២០១៧ (៤ ២៧៨ លានដុល្លារអាមេរិក)។ យោងតាមអត្ថសញ្ញាណនៃតុល្យភាពការទូទាត់ពាណិជ្ជកម្ម រាល់ឱនភាពពាណិជ្ជកម្មត្រូវតែទូទាត់ដោយអតិរេកនៃលំហូរហិរញ្ញវត្ថុ ដូចជា ការវិនិយោគផ្ទាល់ពីបរទេស ជំនួយអភិវឌ្ឍន៍ផ្លូវការ និងប្រាក់ដុល្លារក្នុងវិស័យទេសចរណ៍ដែលហូរចូលមកប្រទេសកម្ពុជា។

**ឱនភាពពាណិជ្ជកម្មកម្ពុជា (គិតជាលានដុល្លារ)**




ប្រភព៖ របាយការណ៍ឆ្នាំ២០១៨ របស់ធនាគារជាតិនៃកម្ពុជា

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### អតិផរណាមានការធ្លាក់ចុះនៅប្រទេសវៀតណាម

យោងតាម[ការិយាល័យស្ថិតិរបស់វៀតណាម]បានបង្ហាញថា អតិផរណានៅវៀតណាមបានធ្លាក់ចុះនៅត្រឹម២,៦% នៅក្នុងខែមករា ឆ្នាំ២០១៩ ដែលធ្លាក់ចុះពី៣% នៅក្នុងខែធ្នូ និងដែលជាតួរលេខទាបបំផុតចាប់តាំងពីខែកក្កដា ឆ្នាំ២០១៧ មក។ ការធ្លាក់ចុះនេះបណ្តាលមកពីការថមថយនៃកំណើនតម្លៃផ្ទះ សម្ភារៈសំណង់ សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ និងទំនិញ និងការធ្លាក់ចុះនៃថ្លៃដឹកជញ្ជូន។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### ការបិទទ្វាររបស់រដ្ឋាភិបាលអាមេរិកបានធ្វើអោយខាតបង់ដល់សេដ្ឋកិច្ច ចំនួន០៣ប៊ីលានដុល្លារអាមេរិក

យោងតាម[ការស្រាវជ្រាវថ្មីមួយ] ដែលធ្វើឡើងដោយការិយាល័យថវិកាសភាអាមេរិក(CBO) ការបិទទ្វាររដ្ឋាភិបាលសហព័ន្ធរបស់លោកប្រធានាធិបតី ត្រាំ ពាក់ព័ន្ធទៅនឹងការចំណាយសាងសង់ជញ្ជាំងព្រំដែន បានកាត់បន្ថយសកម្មភាពសេដ្ឋកិច្ច ដែលគិតជាទឹកប្រាក់ស្មើនឹង០៣ប៊ីលានដុល្លារអាមេរិក។ សេដ្ឋកិច្ចអាមេរិកនៅក្នុងឆ្នាំនេះត្រូវបានរំពឹងថានឹងមានចំនួន ០,០២% ទាបជាងការព្យាករណ៍ជាមូលដ្ឋាន របស់ CBO។

ជារួម CBO បានប៉ាន់ប្រមាណថា សេដ្ឋកិច្ចអាមេរិកបានខាតបង់ចំនួន១១ប៊ីលានដុល្លារអាមេរិក ក្នុងរយៈពេល៥សប្តាហ៍ ដោយសារតែបុគ្គលិករបស់រដ្ឋាភិបាលសហព័ន្ធមិនទទួលបានប្រាក់ខែ។ ទោះជាយ៉ាងណាក៏ដោយ ទឹកប្រាក់ចំនួន ០៨ប៊ីលានដុល្លារអាមេរិកត្រូវបានគេរំពឹងថានឹងទទួលបានមកវិញនៅពេលដែលរដ្ឋាភិបាលបើកទ្វារឡើងវិញ ហើយបុគ្គលិកក៏ទទួលបាននូវប្រាក់ខែត្រឡប់មកវិញ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ ការគ្រប់គ្រងសន្ទស្សន៍ផលិតកម្មរបស់សិង្ហបុរី និងជប៉ុន អតិផរណាប្រទេសហ្វីលីពីន ការវិនិយោគមូលបត្របំណុលបរទេសរបស់ជប៉ុន ទុនបំរុងរូបិយប័ណ្ណក្រៅប្រទេសរបស់សិង្ហបុរី និងចិន។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃចន្ទ ទី០៤ កុម្ភៈ ២០១៩

- ការគ្រប់គ្រងសន្ទស្សន៍ផលិតកម្ម(PMI) Nikkei របស់ម៉ាឡេស៊ី សម្រាប់ខែមករា
- ការគ្រប់គ្រងសន្ទស្សន៍ផលិតកម្ម(PMI) របស់សិង្ហបុរី សម្រាប់ខែមករា

ថ្ងៃអង្គារ ទី០៥ កុម្ភៈ ២០១៩

- ការដេញថ្លៃមូលបត្របំណុលរបស់រដ្ឋាភិបាលជប៉ុនរយៈពេល ១០ ឆ្នាំ
- ការគ្រប់គ្រងសន្ទស្សន៍សេវាកម្ម Nikkei របស់ជប៉ុន សម្រាប់ខែមករា
- អតិផរណារបស់ហ្វីលីពីន សម្រាប់ខែមករា
- ផលិតកម្មឧស្សាហកម្មរបស់ហ្វីលីពីន សម្រាប់ខែធ្នូ
- ការគ្រប់គ្រងសន្ទស្សន៍សេវាកម្ម Nikkei របស់ជប៉ុន សម្រាប់ខែមករា

ថ្ងៃពុធ ទី០៦ កុម្ភៈ ២០១៩

- ភាពជឿជាក់លើពាណិជ្ជកម្មរបស់ឥណ្ឌូនេស៊ី សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨
- ការសម្រេចចិត្តទៅលើអត្រាការប្រាក់របស់ថៃ
- ទំនុកចិត្តរបស់អ្នកប្រើប្រាស់របស់ឥណ្ឌូនេស៊ី សម្រាប់ខែមករា
- ផសស របស់ឥណ្ឌូនេស៊ី សម្រាប់ត្រីមាសទី៤ឆ្នាំ ២០១៨

ថ្ងៃព្រហស្បតិ៍ ទី០៧ ខែកុម្ភៈ ២០១៩

- ការវិនិយោគមូលបត្របំណុលបរទេសរបស់ជប៉ុន ០២/កុម្ភៈ
- ទុនបំរុងរូបិយប័ណ្ណបរទេសរបស់ជប៉ុន សម្រាប់ខែមករា
- ភាពជឿជាក់របស់អ្នកប្រើប្រាស់របស់ថៃ សម្រាប់ខែមករា
- ទុនបំរុងរូបិយប័ណ្ណបរទេសរបស់ចិន សម្រាប់ខែមករា
- ការសម្រេចចិត្តទៅលើអត្រាការប្រាក់របស់ហ្វីលីពីន
- ទុនបំរុងរូបិយប័ណ្ណក្រៅប្រទេសរបស់សឹង្ហបុរី សម្រាប់ខែមករា

ថ្ងៃសុក្រ ទី០៨ ខែកុម្ភៈ ២០១៩

- ទុនបំរុងរូបិយប័ណ្ណរបស់កូរ៉េខាងត្បូង សម្រាប់ខែមករា
- គណនីចរន្តរបស់ជប៉ុន សម្រាប់ខែធ្នូ
- ការចំណាយតាមគ្រួសាររបស់ជប៉ុន សម្រាប់ខែធ្នូ
- ការលក់រាយរបស់ឥណ្ឌូនេស៊ី សម្រាប់ខែធ្នូ
- ការលក់រាយនៅប្រទេសម៉ាឡេស៊ី សម្រាប់ខែធ្នូ